# អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើនារីភេទ

ចែកចាយទូទៅ
ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣
អត្ថបទដើម: អង់គ្លេស

<u>អត្ថបទចុងក្រោយមិនទាន់កែសម្រួល</u>

## គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើនារីភេទ

## *ការសង្កេតសន្និដ្ឋានលើរបាយការណ៍ជាតិតាមពេលកំណត់លើកទី៤ និងទី៥ របស់ប្រទេសកម្ពុជា*

១. គណៈកម្មាធិការបានពិចារណាលើរបាយការណ៍គួបលើកទី៤ និងទី៥ របស់កម្ពុជា (CEDAW/C/KHM/4-5) ក្នុងសម័យប្រជុំលើកទី១១៦៩ និងទី១១៧០ កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ (សូមមើល CEDAW/C/SR. ១១៦៩ និង១១៧០)។ បញ្ជីបញ្ហា និងសំណួររបស់គណៈកម្មាធិការមាននៅក្នុង CEDAW/C/KHM/Q/4-5 និងចម្លើយតបរបស់ប្រទេសកម្ពុជាមាននៅក្នុង CEDAW/C/KHM/Q/4-5/Add.1។

## ក. សេចក្តីផ្តើម

២. គណៈកម្មាធិការស្វាគមន៍ចំពោះរដ្ឋភាគី ដែលបានដាក់ជូនរបាយការណ៍តាមកាលកំណត់លើកទី៤ និងទី៥ ដែលពិចារណាលើការសង្កេតសន្និដ្ឋានមុនៗរបស់គណៈកម្មាធិការ។ គណៈកម្មាធិការសម្តែងការកោតសរសើរចំពោះរដ្ឋភាគីដែលបានធ្វើការបង្ហាញផ្ទាល់មាត់ ឆ្លើយតបជាលាយល័ក្ខអក្សរចំពោះបញ្ជីបញ្ហា និងសំណួរ ដែលត្រូវបានលើកឡើងដោយ ក្រុមការងារមុនសម័យប្រជុំរបស់គណៈកម្មាធិការ ការបំភ្លឺបន្ថែមចំពោះសំណួរដែលត្រូវបានលើកឡើងដោយផ្ទាល់មាត់ដោយគណៈកម្មាធិការ និងពិភាក្សាដោយចំហ និងស្ថាបនា។

៣. គណៈកម្មាធិការសូមសរសើរចំពោះគណៈប្រតិភូជាន់ខ្ពស់របស់រដ្ឋភាគី ដែលដឹកនាំដោយលោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលមានតំណាងចូលរួមពីក្រសួង និងស្ថាប័នពាក់ព័ន្ធមួយចំនួន ដូចជាក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាជ្ញាធរជាតិប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍។ គណៈកម្មាធិការសូមកោតសរសើរ ចំពោះកិច្ចពិភាក្សា ដែលបានប្រព្រឹត្តទៅរវាងគណៈប្រតិភូ និងសមាជិកគណៈកម្មាធិការ។

៤. គណៈកម្មាធិការស្វាគមន៍ចំពោះរដ្ឋភាគី ដែលបានទទួលស្គាល់នូវការរួមចំណែកជាវិជ្ជមាន និងសហប្រតិបត្តិការជាបន្តនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងទីភ្នាក់នានារបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលធ្វើការលើវិស័យសិទ្ធិមនុស្ស និងស្ត្រីក្នុងការអនុវត្តអនុសញ្ញានេះ។

## ខ. ទិដ្ឋភាពជាវិជ្ជមាន

៥. គណៈកម្មាធិការសូមស្វាគមន៍ចំពោះវិធានការនីតិកម្មដូចខាងក្រោមៈ

** ត្រូវបានអនុម័តដោយគណៈកម្មាធិការក្នុងសម័យប្រជុំលើកទី៥៦ (ថ្ងៃទី៣ខែកញ្ញា ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣)*

ក. ការអនុម័តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងខែកុម្ភៈ ឆ្នាំ២០០៨។

ខ. វិសោធនកម្មច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលត្រូវបានអនុម័តនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។

គ. វិសោធនកម្មច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ក្នុងខែធ្នូ ឆ្នាំ២០០៦។

ឃ. ការអនុម័តច្បាប់ស្តីពីឯកពន្ធភាពក្នុងខែកញ្ញា ឆ្នាំ២០០៥ ។

ង. វិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥។

៦. គណៈកម្មាធិការសូមស្វាគមន៍ចំពោះរដ្ឋភាគី ដែលបានចុះហត្ថលេខា ឬផ្តល់សច្ចាប័នលើសន្ធិសញ្ញាខាង ក្រោម ចាប់តាំងពីការពិចារណាលើរបាយការណ៍មុនៈ

ក. អនុសញ្ញាអន្តរជាតិស្តីពីការការពារបុគ្គលគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣។

ខ. អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។

គ. ពិធីសារតាមជម្រើសនៃសន្ធិសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០។

ឃ. ពិធីសារតាមជម្រើសនៃអនុសញ្ញាប្រឆាំងអំពើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោក បន្ទាប ឬទណ្ឌកម្មដទៃទៀតនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៧។

## គ. ចំណុចកង្វល់ និងអនុសាសន៍សំខាន់ៗ

### ស្ថាប័នរដ្ឋសភា

៧. ខណៈដែលអះអាងជាថ្មីទៀតថា រាជរដ្ឋាភិបាលកម្ពុជាមានការទទួលខុសត្រូវចម្បង និងជាពិសេសទទួលខុសត្រូវចំពោះការអនុវត្តដ៏ពេញលេញ នូវកាតព្វកិច្ចរបស់រដ្ឋភាគីក្រោមអនុសញ្ញានេះ គណៈកម្មាធិការសង្កត់ធ្ងន់ថា អនុសញ្ញានេះភ្ជាប់កាតព្វកិច្ចចំពោះស្ថាប័នទាំងអស់របស់រដ្ឋាភិបាល និងស្នើឲ្យរដ្ឋភាគីជំរុញសភារបស់ខ្លួនចាត់វិធានការចាំបាច់ សមស្របទាក់ទងនឹងការអនុវត្តការសង្កេតសន្និដ្ឋានក្នុងអំឡុងពេលនេះ និងរយៈពេលរាយការណ៍បន្ទាប់ស្របតាមអនុសញ្ញានេះ។

## ស្ថានភាពផ្លូវច្បាប់នៃអនុសញ្ញា

៨. គណៈកម្មាធិការរំលឹកដល់ការសង្កេតសន្និដ្ឋានមុនរបស់ខ្លួន (CEDAW/C/KHM/CO/3, កថាខ័ណ្ឌទី៩ និងទី១០) និងខណៈដែលកត់សម្គាល់នូវចម្លើយតបរបស់គណៈប្រតិភូទាក់ទងនឹងការខកខានរបស់រដ្ឋភាគី ក្នុងការបោះពុម្ពផ្សាយអនុសញ្ញានៅក្នុងព្រះរាជកិច្ចនៅតែមានកង្វល់នៅឡើយ ដោយអនុសញ្ញានេះមិនត្រូវបានបញ្ចូលក្នុងប្រព័ន្ធច្បាប់ជាតិ។ គណៈកម្មាធិការកត់សម្គាល់ដោយក្តីកង្វល់ ថារដ្ឋភាគីមិនបានចុះផ្សាយ អំពីពិធីសារតាមជម្រើសនៃអនុសញ្ញាក្នុងព្រះរាជកិច្ចបន្ទាប់ពីបានចុះហត្ថលេខាលើពិធីសារតាមជម្រើស នេះក្នុងខែតុលា ឆ្នាំ២០១០។

៩. **គណៈកម្មាធិការបញ្ជាក់ឡើងវិញលើអនុសាសន៍មុនៗរបស់ខ្លួន (CEDAW/C/KHM/CO/3, កថាខណ្ឌទី១០) និងផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីបោះពុម្ពផ្សាយអនុសញ្ញា និងពិធីសារតាមជម្រើសក្នុងព្រះរាជកិច្ចដោយឥតបង្អង់តទៅទៀត និងបន្តពិនិត្យឡើងវិញលើនីតិកម្មដើម្បីបញ្ចូលបញ្ញត្តិទាំងអស់របស់អនុសញ្ញាទៅក្នុងច្បាប់ជាតិ។**

## ក្របខ័ណ្ឌច្បាប់ និងការអនុវត្តអនុសញ្ញា

១០. គណៈកម្មាធិការកត់សម្គាល់ ដោយកង្វល់នូវចម្លើយតបរបស់គណៈប្រតិភូ ដែលថារដ្ឋភាគីយល់ថា វាពុំមានការចាំបាច់ក្នុងការកែប្រែច្បាប់របស់ខ្លួនតាមរយៈការប្រើប្រាស់នូវនិយមន័យដ៏គ្រប់ជ្រុងជ្រោយនៃការរើសអើង ដែលហាមឃាត់នូវការរើសអើងដោយផ្ទាល់ និងដោយប្រយោល។ គណៈកម្មាធិការក៏មានកង្វល់ផងដែរ ដោយរដ្ឋភាគីពុំទាន់មានសំណុំរឿងណាមួយពាក់ព័ន្ធនឹងការរើសអើងលើស្ត្រីនៅក្នុង តុលាការរបស់រដ្ឋភាគីនៅឡើយ។

១១. **គណៈកម្មាធិការបញ្ជាក់ឡើងវិញលើអនុសាសន៍មុនរបស់ខ្លួន (CEDAW/C/KHM/CO/3 កថាខ័ណ្ឌទី១២) និងផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីពិចារណាលើការអនុវត្តក្របខណ្ឌច្បាប់គ្រប់គ្រងសមភាពយេនឌ័រដែលគួរតែបញ្ចូលនិយមន័យនៃការរើសអើងលើស្ត្រី ដែលគ្របដណ្តប់លើការរើសអើងដោយផ្ទាល់ និងដោយប្រយោលស្របតាមមាត្រា១នៃអនុសញ្ញា។ គណៈកម្មាធិការបញ្ជាក់ឡើងវិញលើអនុសាសន៍លើកមុន របស់ខ្លួន (CEDAW/C/KHM/CO/3 កថាខណ្ឌទី១០) ដែលស្នើឲ្យរដ្ឋភាគីពង្រឹងវិធានការរបស់ខ្លួនក្នុងការ បង្កើតការយល់ដឹងអំពីអនុសញ្ញា និងពិធីសារតាមជម្រើសក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា និងមេធាវី និងបន្តបញ្ចូលការបណ្តុះបណ្តាលស្តីពីអនុសញ្ញាក្នុងកម្មវិធីអប់រំពាក់ព័ន្ធសម្រាប់មន្ត្រីរាជការ មន្ត្រីតុលាការ និងអ្នកដែលបានប្រើប្រាស់ក្នុងប្រព័ន្ធអប់រំ។**

## ជំនួយផ្នែកច្បាប់ និងការទទួលបានយុត្តិធម៌

១២. គណៈកម្មាធិការមានកង្វល់អំពីរបាយការណ៍ ដែលលើកឡើងថារដ្ឋភាគីខ្វះប្រព័ន្ធជំនួយផ្នែកច្បាប់គ្រប់ជ្រុងជ្រោយ ដែលប្រការនេះ មានឥទ្ធិពលជាអវិជ្ជមានទៅលើការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី ហើយស្ត្រីត្រូវចំណាយប្រាក់បន្ថែមទៅលើតុលាការ ដោយសារការប្រព្រឹត្តអំពើពុករលួយនៅពេលដំណើរការរឿងក្តីរបស់ពួកគេ។ គណៈកម្មាធិការក៏មានកង្វល់ផងដែរ ដោយជំនួយផ្នែកច្បាប់ភាគច្រើនត្រូវបានផ្តល់ ដោយអង្គការមិនមែនរដ្ឋាភិបាល ហើយថវិកាដែលផ្តល់ដោយរដ្ឋភាគីដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់បម្រើគោលបំណងនេះ មានចំនួនមិនគ្រប់គ្រាន់។

១៣. គណៈកម្មាធិការសូមទទូចឲ្យរដ្ឋភាគី:

(ក) បង្កើតគម្រោងជំនួយផ្នែកច្បាប់គ្រប់ជ្រុងជ្រោយ ដើម្បីធានាថាស្ត្រីទទួលបានសេវាប្រកបដោយប្រសិទ្ធភាពពីតុលាការ និងសាលាជម្រះក្តី ស្របតាមគោលការណ៍ និងការណែនាំរបស់អង្គការសហប្រជាជាតិ ស្តីពីការទទួលបានជំនួយផ្នែកច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ (សេចក្តីសម្រេចលេខ ៦៧/១៨៧ របស់មហាសន្និបាតអង្គការសហប្រជាជាតិ) ជាពិសេសគោលការណ៍ណែនាំទី៩ ស្តីពីការអនុវត្តសិទ្ធិរបស់ស្ត្រីក្នុងការទទួលបានជំនួយផ្នែកច្បាប់។

(ខ) ផ្តល់ថវិកាគ្រប់គ្រាន់ដល់គណៈមេធាវី និងអង្គការរបស់ស្ត្រី ដែលផ្តល់ការប្រឹក្សាផ្នែកច្បាប់ដោយឥតគិតថ្លៃដើម្បីធានាបាននូវការទទួលបានយុត្តិធម៌ប្រកបដោយប្រសិទ្ធភាពសម្រាប់ ស្ត្រី និង

(គ) បន្តស៊ើបអង្កេត និងចោទប្រកាន់លើករណីពុករលួយក្នុងតុលាការ និងប្រសិនបើអាចអនុវត្ត បានផ្តន្ទាទោសអ្នកប្រព្រឹត្ត។

១៤. គណៈកម្មាធិការមានការព្រួយបារម្ភ ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) មិនបានដោះស្រាយគ្រប់គ្រាន់នូវករណីអំពើហិង្សាផ្តោតលើយេនឌ័រ ជាពិសេសអំពើហិង្សាផ្លូវភេទលើស្ត្រី ដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម។ គណៈកម្មាធិការមានការព្រួយបារម្ភដែលរដ្ឋភាគីខ្វះយន្តការផ្សេងទៀត រាប់បញ្ចូលទាំងកម្មវិធីក្រៅពីផ្លូវតុលាការក្នុងការផ្តល់សំណងប្រកប ដោយប្រសិទ្ធភាពដល់ជនរងគ្រោះនៃអំពើហិង្សាផ្តោតលើយេនឌ័រក្នុងទម្រង់ផ្សេងទៀត ដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម។ គណៈកម្មាធិការក៏មានកង្វល់ផងដែរ ចំពោះការខកខានរបស់រដ្ឋភាគីក្នុងការបញ្ចូលបញ្ញត្តិរបស់អនុសញ្ញា និងសេចក្តីសម្រេចលេខ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក្នុងកម្មវិធី ក្រោយជម្លោះរបស់ខ្លួន។

១៥. គណៈកម្មាធិការទទូចឲ្យរដ្ឋភាគី:

(ក) ផ្តល់សំណងប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះ នៃអំពើហិង្សាផ្តោតលើយេនឌ័រ ជាពិសេសអំពើហិង្សាផ្លូវភេទលើស្ត្រីដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម និងរៀបចំកម្មវិធីយុត្តិធម៌អន្តរកាលមិនមែនតាមផ្លូវតុលាការ រាប់បញ្ចូលទាំងការផ្តល់សំណងជួសជុលគ្រប់គ្រាន់ ការគាំទ្រផ្លូវចិត្ត និងការគាំទ្រសមស្របផ្សេងទៀត និង

(ខ) ឆ្លៀតឱកាសទាញយកផលប្រយោជន៍ពីដំណើរការធ្វើសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) ដំណាក់កាលទី២ ដើម្បីបញ្ចូលបញ្ញត្តិនៃអនុសញ្ញា និងសេចក្តីសម្រេចលេខ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឲ្យបានពេញលេញ។

## យន្តការជាតិសម្រាប់ការលើកកម្ពស់ស្ត្រី

១៦. គណៈកម្មាធិការស្វាគមន៍ចំពោះការវាយតម្លៃលើសមត្ថភាពរបស់យន្តការជាតិ សម្រាប់ការលើកកម្ពស់ស្ត្រី និងការបង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAGs) ក្នុងក្រសួងស្ថាប័នផ្សេងៗជាយន្តការសម្រាប់ការអនុវត្ត និងពិនិត្យតាមដានការប្តេជ្ញាចិត្តលើគោលនយោបាយសមភាពយេនឌ័រផ្អែកលើផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ២០០៦-២០១០។ ប៉ុន្តែគណៈកម្មាធិការមានការព្រួយបារម្ភអំពីការខ្វះខាតកិច្ចសហការរវាងយន្តការជាតិសម្រាប់ការលើកកម្ពស់ស្ត្រី និងក្រុមការងារបញ្ជ្រាបយេនឌ័រតាមវិស័យ។ គណៈកម្មាធិការ មានកង្វល់បន្ថែមទៀតថា ថវិកាដែល

ត្រូវបានបែងចែកសម្រាប់យន្តការជាតិសម្រាប់ការលើកកម្ពស់ស្ត្រីមានចំនួនមិនគ្រប់គ្រាន់ បើពិចារណាលើភារកិច្ចដ៏ទូលំទូលាយរបស់យន្តការនេះ។

**១៧.គណៈកម្មាធិការអំពាវនាវឲ្យរដ្ឋភាគីបន្តធ្វើសុខុដុមនីយកម្ម និងពង្រឹងយន្តការជាតិសម្រាប់ការលើកកម្ពស់ស្ត្រី។ គណៈកម្មាធិការក៏សូមផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីបង្កើនការបែងចែកថវិកាសម្រាប់យន្តការជាតិ ហើយយន្តការនេះនឹងធានាថា ធនធានមានស្របទៅតាមភារកិច្ច និងសកម្មភាពរបស់ខ្លួន។ រដ្ឋភាគីក៏គប្បីធានាថាការបែងចែកថវិកាត្រូវបានពិនិត្យវាយតម្លៃជារៀងរាល់ឆ្នាំ និងកែតម្រូវ តាមការចាំបាច់។**

## ទស្សនៈតាមទម្លាប់(ផ្នត់គំនិត)

១៨.ទន្ទឹមនឹងការកោតសរសើររដ្ឋភាគី ចំពោះកិច្ចប្រឹងប្រែងក្នុងការកែសម្រួលកម្មវិធីសិក្សាតាមសាលារៀន និងសៀវភៅសិក្សាក្នុងគោលបំណងលុបបំបាត់ផ្នត់គំនិតយេនឌ័រ គណៈកម្មាធិការនៅមានកង្វល់នៅឡើយ ដោយច្បាប់ស្រីដែលជាក្រមអនុវត្តបែបប្រពៃណីសម្រាប់ស្ត្រីបានចាក់ឫសយ៉ាងជ្រៅក្នុងវប្បធម៌ខ្មែរ និងបន្តកំណត់នូវជីវិតប្រចាំថ្ងៃក្នុងសង្គមផ្អែកលើតួនាទីតាមទម្លាប់របស់ស្ត្រី និងបុរសនៅក្នុងគ្រួសារ និងសង្គម។

**១៩. គណៈកម្មាធិការបញ្ជាក់ឡើងវិញលើអនុសាសន៍មុនរបស់ខ្លួន(CEDAW/C/KHM/CO/3 កថាខណ្ឌទី១៨) និងផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី:**

**(ក) បញ្ចូលយុទ្ធសាស្ត្រ ដែលមានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ដែលមានគោលបំណងកែសម្រួល ឬលុបបំបាត់ផ្នត់គំនិតបិតាធិបតេយ្យ និងទស្សនៈតាមទម្លាប់ ដែលរើសអើងលើស្ត្រីរាប់បញ្ចូលទាំងផ្នត់គំនិត និងទស្សនៈតាមទម្លាប់ផ្អែកលើច្បាប់ស្រី**

**(ខ) ធ្វើយុទ្ធនាការផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈទូទាំងប្រទេស និងជំរុញកិច្ចពិភាក្សាសាធារណៈឲ្យបានទូលំទូលាយ ដើម្បីដោះស្រាយផ្នត់គំនិត និងទស្សនៈតាមទម្លាប់ដែលរើសអើងលើស្ត្រី ដោយសហការជាមួយសង្គមស៊ីវិល អ្នកដឹកនាំសហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ។**

**(គ) សិក្សាពិនិត្យលើការប្រើប្រាស់បច្ចេកវិទ្យាសារគមនាគមន៍ ព័ត៌មាន រាប់បញ្ចូលទាំងបណ្តាញព័ត៌មានសង្គម ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិស្ត្រី និងសមភាពយេនឌ័រ និង**

**(ឃ) បង្កើតយន្តការពិនិត្យតាមដាន និងវាយតម្លៃដែលមានប្រសិទ្ធភាពក្នុងគោលបំណងវាយតម្លៃវឌ្ឍនភាព ក្នុងការលុបបំបាត់ផ្នត់គំនិតយេនឌ័រដែលមានស្រាប់។**

## អំពើហិង្សាលើស្ត្រី

២០. គណៈកម្មាធិការទទួលស្គាល់វិធានការ ដែលត្រូវបានចាត់ឡើងដោយរដ្ឋភាគីក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) ដំណាក់កាលទី២ ដែលប្រើប្រាស់មេរៀនបទពិសោធន៍ដែលទទួលបានពីការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) ដំណាក់កាលទី១ ឆ្នាំ២០០៩-២០១២។ ទោះជាយ៉ាងនេះក្តី គណៈកម្មាធិការសោកស្តាយ ដែលមានវឌ្ឍនភាពតិចតួចលើការងារទប់ស្កាត់ និងលុបបំបាត់អំពើហិង្សាលើស្ត្រី ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ គណៈកម្មាធិការនៅមានកង្វល់នៅឡើយ ដែលការខ្វះទំនុកចិត្តរបស់សាធារណជនលើប្រព័ន្ធយុត្តិធម៌ និងឥរិយាបថអវិជ្ជមានរបស់មន្ត្រី

តុលាការ និងមន្ត្រីអនុវត្តច្បាប់ចំពោះជនរងគ្រោះ ដោយអំពើហិង្សានៅតែបន្តរាំងដល់ការចោទប្រកាន់ប្រកបដោយប្រសិទ្ធភាពលើករណីនានា។ ខណៈដែលកត់សម្គាល់នូវការពន្យល់របស់រដ្ឋភាគីទាក់ទងនឹងការអនុវត្តរបស់ខ្លួនក្នុងការដោះស្រាយករណី អំពើហិង្សាលើស្ត្រីតាម រយៈការសម្រុះសម្រួលគណៈកម្មាធិការព្រួយបារម្ភ ថាការអនុវត្តន៍បែបនេះ អាចធ្វើឲ្យស្ត្រីមិនហ៊ានប្ដឹងជនល្មើសតាមផ្លូវច្បាប់ទោះបីជាបណ្ដឹងនោះត្រូវបានជានាក់ដោយ។ គណៈកម្មាធិការក៏មានកង្វល់ផងដែរចំពោះការខ្វះខាតទិន្នន័យអំពីចំនួនដីកាការពារ ដែលត្រូវបានចេញដោយតុលាការក្នុងអំឡុងពេលធ្វើរបាយការណ៍ និងអំពីទីជម្រកដែលមានសម្រាប់ស្ត្រី ដែលជាជនរងគ្រោះដោយអំពើហិង្សា។

២១. ដោយរំលឹកឡើងវិញនូវអនុសាសន៍ទូទៅលេខ១៩ (ឆ្នាំ១៩៩២) ស្ដីពីអំពើហិង្សាលើស្ត្រី និងអនុសាសន៍មុនរបស់ខ្លួន (CEDAW/C/KHM/CO/3 កថាខណ្ឌ១៦) គណៈកម្មាធិការជំរុញឲ្យរដ្ឋភាគី:

(ក) បង្កើនកិច្ចប្រឹងប្រែងក្នុងការបណ្ដុះបណ្ដាលមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់អំពីការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឲ្យបានហ្មត់ចត់ដើម្បីធានាថាករណីអំពើហិង្សាលើស្ត្រី រាប់បញ្ចូលទាំងអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទត្រូវបានចោទប្រកាន់ប្រកបដោយប្រសិទ្ធភាព និងមិនត្រូវបានបង្វែរ ទៅជាការសម្រុះសម្រួលជាលក្ខណៈប្រព័ន្ធ។

(ខ) លើកទឹកចិត្តស្ត្រីឲ្យដាក់បណ្ដឹងជាផ្លូវការលើអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទតាមរយៈការលុបបំបាត់ការមាក់ងាយលើជនរងគ្រោះ និងការលើកកម្ពស់ការយល់ដឹងអំពីលក្ខណៈព្រហ្មទណ្ឌនៃអំពើបែបនេះ។

(គ) បន្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីអំពើហិង្សាលើស្ត្រីគ្រប់រូបភាពជាពិសេសនៅតំបន់ជនបទ និង

(ឃ) ផ្ដល់ព័ត៌មានអំពីចំនួនដីកាការពារ ដែលត្រូវបានចេញដោយតុលាការក្នុងអំឡុងពេលរាយការណ៍ និងចំនួនទីជម្រកដែលមានសម្រាប់ស្ត្រី ដែលជាជនរងគ្រោះដោយអំពើហិង្សានៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយ។

២២. គណៈកម្មាធិការកត់សម្គាល់នូវកិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការដាក់ចេញវិធានការលើកលែងការបង់ថ្លៃសេវាសម្រាប់ការពិនិត្យកោសល្យវិច្ច័យរបស់ជនរងគ្រោះ ដោយអំពើរំលោភសេពសន្ថវៈ។ ទោះជាយ៉ាងនេះក្ដី គណៈកម្មាធិការនៅមានកង្វល់ចំពោះរបាយការណ៍ជាបន្តអំពីអំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌ និងថ្លៃចំណាយខ្ពស់លើលិខិតបញ្ជាក់សុខភាពសម្រាប់អំពើរំលោភសេពសន្ថវៈ និងការបំពានផ្លូវភេទ ដែលនៅតែបន្តរាំងមិនឲ្យស្ត្រីទទួលបានយុត្តិធម៌ និងរាំងដល់ការចោទប្រកាន់លើករណីអំពើហិង្សាលើស្ត្រី។

២៣. គណៈកម្មាធិការផ្ដល់អនុសាសន៍ឲ្យរដ្ឋភាគីពង្រឹងកិច្ចប្រឹងប្រែងលើការលើកកម្ពស់ការយល់ដឹងក្នុងចំណោមគ្រូពេទ្យអំពីរបៀបគ្រប់គ្រងករណីអំពើហិង្សាលើស្ត្រី។ រដ្ឋភាគីក៏គប្បីលើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្ដីពីការលើកលែងការបង់ថ្លៃសម្រាប់រាល់ការពិនិត្យកោសល្យវិច្ច័យរបស់ជនរងគ្រោះ ដោយអំពើរំលោភសេពសន្ថវៈ និងការបំពានផ្លូវភេទ។

## អំពើជួញដូរ និងអំពើធ្វើអាជីវកម្មពេស្យាកម្ម

២៤. គណៈកម្មាធិការកត់សម្គាល់នូវការវាយតម្លៃលើប្រសិទ្ធភាព នៃវិធានការប្រឆាំងអំពើជួញដូរ

ស្របតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការបង្កើតក្រុមការងារពិសេស ដែលមានភារកិច្ចពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការប្រឆាំងការជួញដូរមនុស្ស។ ប៉ុន្តែគណៈកម្មាធិការមានកង្វល់ដែលការអនុវត្តច្បាប់នេះ ជាទូទៅមិនទាន់មានប្រសិទ្ធភាព។ គណៈកម្មាធិការមានកង្វល់ជាពិសេសថា អំពើជួញដូរមនុស្សនៅតែត្រូវបានធ្វើឲ្យធ្ងន់ធ្ងរជាបន្ត ដោយការអនុវត្តរបស់ទីភ្នាក់ងារបោកប្រាស់ដែលជ្រើសរើសស្ត្រី និងក្មេងស្រីសម្រាប់គោលបំណងនៃការធ្វើអាជីវកម្មផ្លូវភេទ និងការបម្រើតាមផ្ទះនៅក្នុងប្រទេសជិតខាង និងការខ្វះខាតទិន្នន័យអំពីពលករ ពលការិនី ទេសន្តប្រវេសន៍បម្រើការងារតាមផ្ទះដែលជាជនរងគ្រោះដោយអំពើជួញដូរ។ គណៈកម្មាធិការក៏ព្រួយបារម្ភផងដែរចំពោះការខ្វះខាតព័ត៌មានអំពីយន្តការជាតិសម្រាប់ការបញ្ជូន [ជនរងគ្រោះទៅរកសេវា] ដែលផ្តោតលើការស្រាវជ្រាវការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរឲ្យបានទាន់ពេល និងការគាំទ្រសម្រាប់ពលករ ពលការិនីទាំងនោះ។

២៥. គណៈកម្មាធិការទទូចឲ្យរដ្ឋភាគី:

(ក) ពង្រឹងការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

(ខ) បង្កើនការផ្សព្វផ្សាយព័ត៌មានអំពីទេសន្តប្រវេសន៍ដើម្បីការងារ និងផ្តល់ព័ត៌មានអំពីក្រុមហ៊ុនបោកប្រាស់ដែលជ្រើសរើសពលករ ពលការិនី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។

(គ) ធានាថា អ្នកជួញដូរមនុស្ស និងអ្នកដទៃទៀតដែលទទួលខុសត្រូវចំពោះអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងក្មេងស្រី ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសប្រកបដោយប្រសិទ្ធភាព និង

(ឃ) ពង្រឹងសហប្រតិបត្តិការទ្វេភាគី និងពហុភាគីក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សសម្រាប់ការងារបម្រើតាមផ្ទះ និងអំពើ ធ្វើអាជីវកម្មផ្លូវភេទ។

(ង) បញ្ចូលទិន្នន័យអំពីពលករ ពលការិនីទេសន្តប្រវេសន៍បម្រើការងារតាមផ្ទះ ដែលជាជនរងគ្រោះ ដោយអំពើជួញដូរ ព័ត៌មានអំពីយន្តការជាតិសម្រាប់ការបញ្ជូន ប្រសិនបើមានក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយ និងធានាថាជនរងគ្រោះដោយអំពើជួញដូរត្រូវបានកំណត់អត្តសញ្ញាណ សមស្របត្រូវបានគាំទ្រគ្រប់គ្រាន់ និងការពារពីការជួញដូរ។

២៦. គណៈកម្មាធិការមានកង្វល់ចំពោះវិធានការ ដែលត្រូវបានចាត់ឡើងដោយរដ្ឋភាគីក្នុងការដោះស្រាយមូលហេតុដែលជាឫសគល់នៃពេស្យាកម្មពុំមានប្រសិទ្ធភាព។ គណៈកម្មាធិការក៏ព្រួយបារម្ភផងដែរ ចំពោះរបាយការណ៍ ថាមន្ត្រីអនុវត្តច្បាប់បំពារបំពានផ្លូវភេទលើស្ត្រីរកស៊ីផ្លូវភេទនៅពេលដែលស្ត្រីទាំងនោះ ស្ថិតក្រោមការឃុំខ្លួនរបស់មន្ត្រីអនុវត្តច្បាប់។

២៧. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីចាត់វិធានការ ដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយមូលហេតុជាឫសគល់ នៃពេស្យាកម្មរាប់បញ្ចូលទាំងតាមរយៈការផ្តល់កម្មវិធី សំរាប់ស្ត្រីដែលមានបំណងចាកចេញពីការរកស៊ីផ្លូវភេទ។ លើសពីនេះទៀត រដ្ឋភាគីគប្បីស៊ើបអង្កេត និងចោទប្រកាន់ករណីបំពានផ្លូវភេទដោយមន្ត្រីអនុវត្តច្បាប់ ដែលបានប្រព្រឹត្តលើស្ត្រីរកស៊ីផ្លូវភេទ និងធានាថាជនល្មើសត្រូវបានផ្តន្ទាទោសដោយទណ្ឌកម្មសមស្រប។ គណៈកម្មាធិការក៏សូមផ្តល់អនុសាសន៍ផងដែរឲ្យរដ្ឋភាគីបង្កើតគោលនយោបាយដ៏គ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបនឹងបញ្ហាដែលទាក់ទងនឹងតម្រូវការពេស្យាចារ និងពិចារណាលើការដាក់ទណ្ឌកម្មលើអ្នកទិញសេវាផ្លូវភេទ។

## ការចូលរួមក្នុងវិស័យនយោបាយ និងសាធារណៈ

២៨. ខណៈដែលកត់សម្គាល់នូវកិច្ចប្រឹងប្រែងរបស់រដ្ឋភាគីក្នុងការបង្កើនការចូលរួមរបស់ស្ត្រីនៅគ្រប់កម្រិត និងក្នុងវិស័យតុលាការ គណៈកម្មាធិការនៅតែមានកង្វល់ ថាស្ត្រីនឹងមានតំណាងតិចតួចជាបន្តនៅក្នុងកិច្ចការនយោបាយ និងកិច្ចការសាធារណៈគ្រប់កម្រិត និងក្នុងកិច្ចការទូត និងកិច្ចការក្រៅប្រទេស។ គណៈកម្មាធិការមានកង្វល់ ជាពិសេសដែលចំនួនតំណាងជាស្ត្រីនៅក្នុងរដ្ឋសភាបានថយចុះបន្ទាប់ពីការបោះ ឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលបានប្រព្រឹត្ត កាលខែកក្កដា ឆ្នាំ២០១៣។

២៩. **គណៈកម្មាធិការបញ្ជាក់ឡើងវិញលើការសង្កេតសន្និដ្ឋានមុនៗរបស់ខ្លួន (CEDAW/C/KHM/CO/3 កថា ខណ្ឌទី១៤) និងជម្រុញឲ្យរដ្ឋភាគីធានាថា ផែនការនារីរតនៈទី៤ ផ្តល់នូវយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព រាប់បញ្ចូលទាំងវិធានការពិសេសបណ្តោះអាសន្ន ដែលមានគោលបំណងបង្កើនតំណាងរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្តជាពិសេសក្នុងកិច្ចការនយោបាយ តុលាការ ការទូត និងការបទេស។**

## សញ្ជាតិ

៣០. គណៈកម្មាធិការមានការព្រួយបារម្ភ ដែលស្ត្រីជនជាតិវៀតណាមទទួលរងនូវការលំបាកច្រើនក្នុងការចុះបញ្ជីកំណើត និងការទទួលបានសញ្ជាតិកម្ពុជា ដែលធ្វើឲ្យពួកគេប្រឈមនឹងភាពគ្មានរដ្ឋ។

៣១. **គណៈកម្មាធិការអំពាវនាវឲ្យរដ្ឋភាគី:**

(ក) **បង្កើនកិច្ចប្រឹងប្រែង ក្នុងការជួយសម្រួលដល់ការចុះបញ្ជីកំណើតកូនរបស់ស្ត្រីវៀតណាម និងការទទួលបានសញ្ជាតិ និង**

(ខ) **ពិចារណាលើការចុះហត្ថលេខាលើសន្ធិសញ្ញាឆ្នាំ១៩៥១ ស្តីពីស្ថានភាពរបស់ជនដែល គ្មានរដ្ឋ និង អនុសញ្ញាឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានរដ្ឋ។**

## ការអប់រំ

៣២. គណៈកម្មាធិការកត់សម្គាល់នូវការប្រឹងប្រែង ដែលត្រូវបានធ្វើឡើងក្នុងការបង្កើនអក្ខរកម្មរបស់ស្ត្រី និងការផ្តល់ការអប់រំពីរភាសា និងអាហារូបករណ៍ដល់កុមារី។ ទោះបីជាយ៉ាងនេះក្តី គណៈកម្មាធិការមានការ ព្រួយបារម្ភចំពោះគុណភាពនៃការអប់រំនៅក្នុងរដ្ឋភាគី និងអត្រាបាត់បង់កម្រិតខ្ពស់រវាងកម្រិតបឋមសិក្សា និងមធ្យមសិក្សា ជាពិសេសក្នុងតំបន់ជនបទដាច់ស្រយាលដោយសារតែសមត្ថភាពមានកម្រិតនៅកម្រិតមធ្យមសិក្សា។ ដូច្នេះគណៈកម្មាធិការមានការព្រួយបារម្ភ ដែលឃុំមួយចំនួនធំមិនមានអនុវិទ្យាល័យ ដោយសារកត្តាភូមិសាស្ត្រ និងកត្តាប្រជាសាស្ត្រ ដែលបង្ខំឲ្យសិស្សស្រីបញ្ឈប់ការសិក្សា ដោយសារពួកគេ មិនអាចធ្វើចំណាកស្រុកចេញទៅតំបន់ទីប្រជុំជន ដើម្បីទទួលបានការអប់រំកម្រិតនេះ។ គណៈកម្មាធិការ មានការព្រួយបារម្ភ ដែលសូម្បីតែនៅទីកន្លែងដែលសិស្សស្រីត្រូវបានផ្តល់ទីស្នាក់អាស្រ័យ អត្រាបោះបង់ការសិក្សាក្នុងចំណោមសិស្សស្រី ទោះបីជាមានការធ្លាក់ចុះក៏ដោយក៏នៅមានកម្រិតខ្ពស់គួរឲ្យកត់សម្គាល់នៅឡើយ នៅពេលដែលពួកគេឆ្លងពីបឋមសិក្សាទៅមធ្យមសិក្សា និងពីមធ្យមសិក្សាទៅឧត្តមសិក្សា ដែលរដ្ឋភាគីសន្មតថាកត្តាទាំងនេះបណ្តាលមកពីភាពក្រីក្រ ការចុះឈ្មោះចូលរៀនយឺតយ៉ាវ និងការមានគភ៌នៅវ័យក្មេង។

៣៣. **គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី:**

(ក) **ចាត់វិធានការដែលមានប្រសិទ្ធភាព ដើម្បីបង្កើនការទទួលបានការអប់រំសម្រាប់កុមារី រាប់បញ្ចូលទាំងតាមរយៈការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនឱកាសនៅក្នុងសាលាមធ្យម**

សិក្សា ជាពិសេសនៅក្នុងឃុំ។

(ខ) រៀបចំបង្កើតវិធានការនានា សំដៅធានាឲ្យបាននូវការរក្សាស្ត្រី និងកុមារីឲ្យបាននៅក្នុងសាលា ជាពិសេសនៅពេលឆ្លងពីបឋមសិក្សាទៅមធ្យមសិក្សា និងកម្រិតឧត្តមសិក្សា។

(គ) បង្កើនការអប់រំ ដែលសមស្របតាមអាយុអំពីសិទ្ធិផ្លូវភេទ និងសិទ្ធិបន្តពូជនៅតាមសាលារៀន អំពីទំនាក់ទំនងយេនឌ័រ និងការប្រព្រឹត្តផ្លូវភេទដែលមានការទទួលខុសត្រូវ ដើម្បីទប់ស្កាត់ការមានគភ៌វ័យក្មេង និង

(ឃ) លើកកម្ពស់គុណភាពនៃការអប់រំ តាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀន និងធានាថាគ្រូបង្រៀន ទទួលបានប្រាក់បំណាច់គ្រប់គ្រាន់។

## ការងារ/មុខរបរ និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច

៣៤. គណៈកម្មាធិការរំលឹកឡើងវិញអំពីការសង្កេតសន្និដ្ឋានមុនរបស់ខ្លួន (CEDAW/C/KHM/CO/3 កថាខណ្ឌទី១៦) និងនៅមានការព្រួយបារម្ភចំពោះការបែងចែកមុខរបរជាបន្ត និងការប្រមូលផ្តុំស្ត្រីដែលធ្វើការមិនមានជំនាញ ហើយទទួលបានប្រាក់ឈ្នួលទាប រួមទាំងបញ្ហាគម្លាតប្រាក់បៀវត្សរបស់បុរស និងស្ត្រីដែលមានតាំងពីយូរស្រាប់។ គណៈកម្មាធិការមានការព្រួយបារម្ភជាពិសេសចំពោះលក្ខខណ្ឌការងារមិនល្អសម្រាប់ស្ត្រី ដែលធ្វើការនៅក្នុងឧស្សាហកម្មកាត់ដេរ និងស្ត្រីបម្រើការងារតាមផ្ទះ រាប់ទាំងស្ត្រីចំណាកស្រុកផង។

៣៥. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីៈ

(ក) បន្តអនុវត្តវិធានការប្រតិសកម្ម និងជាក់ស្តែង ក្នុងការលុបបំបាត់ការបែងចែកមុខងារ និងបញ្ចប់គម្លាត ប្រាក់ឈ្នួល

(ខ) ចាត់វិធានការដើម្បីធានាថា ច្បាប់ការងារត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងបង្កើនចំនួននៃអធិការការងារដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីជួយឲ្យដល់ក្នុងការពិនិត្យតាមដានល័ក្ខខ័ណ្ឌការងាររបស់ស្ត្រីប្រកបដោយប្រសិទ្ធភាព ជាពិសេសក្នុងឧស្សាហកម្មកាត់ដេរ និងវិស័យដែលមានប្រាក់ឈ្នួលទាប និង

(គ) ពិចារណាលើការងារសមរម្យសម្រាប់កម្មករ កម្មការិនីបម្រើការងារតាមផ្ទះស្របតាមអនុសញ្ញាលេខ១៨៩ របស់អង្គការពលកម្មអន្តរជាតិ និងអនុសញ្ញាស្តីពីការការពារកម្មករទេសន្តប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ។

## សុខាភិបាល

៣៦. ខណៈដែលកត់សម្គាល់នូវកិច្ចប្រឹងប្រែងរបស់រដ្ឋភាគីក្នុងការកាត់បន្ថយមរណភាពមាតា និងទារក គណៈកម្មាធិការមានការព្រួយបារម្ភ ចំពោះភាពមិនអាចរកបាននៃមធ្យោបាយពន្យារកំណើតទំនើប និងប្រេវ៉ាឡង់នៃការរំលូតកូន ដែលគ្មានសុវត្ថិភាពដែលរួមចំណែកចំពោះមរណភាពមាតា។ ទោះបីជាមានវឌ្ឍនភាពលើការកាត់បន្ថយការចម្លងមេរោគអេដស៍ គណៈកម្មាធិការនៅព្រួយបារម្ភនៅឡើយ ដែលមានករណីថ្មីនៃការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (MTCT) និងករណីឆ្លងថ្មីដែលប៉ះពាល់ដល់ប្រជាជនងាយរងគ្រោះ ដូចជាស្ត្រីរកស៊ីផ្លូវភេទ។ គណៈកម្មាធិការក៏ព្រួយបារម្ភផងដែរ ចំពោះការរើសអើងលើស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងសម្ពាធដែលគ្រូពេទ្យដាក់ទៅលើពួកគេក្នុងការរំលូតកូន។ គណៈកម្មាធិការព្រួយបារម្ភបន្ថែមទៀត ចំពោះការទទួលបានមានកម្រិតនូវសេវាសុខភាពផ្លូវភេទ និងសេវា

សុខភាពបន្តពូជ ជាពិសេសសម្រាប់ស្ត្រីជនបទ។

៣៧. **គណៈកម្មាធិការអំពាវនាវឲ្យរដ្ឋភាគី:**

**(ក) ធានាថា មធ្យោបាយរំលូតកូនទំនើបដែលមានសុវត្ថិភាពផ្នែកវេជ្ជសាស្ត្រអាចរកបាន និងអាចប្រើប្រាស់ស្របតាមអនុសាសន៍ទូទៅលេខ២៤ (ឆ្នាំ២០០៤) ស្តីពីស្ត្រី និងកុមារ**

**(ខ) ផ្តល់ការព្យាបាលដោយថ្នាំប្រឆាំងនឹងមេរោគអេដស៍ដល់ស្ត្រី និងបុរស ដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ រាប់បញ្ចូលទាំងស្ត្រីរកស៊ីផ្លូវភេទ និងស្ត្រីមានផ្ទៃពោះ ដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន**

**(គ) ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការរើសអើងលើស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ និង**

**(ឃ) បង្កើនការផ្តល់ព័ត៌មាន និងសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជដល់ស្ត្រី រាប់បញ្ចូលទាំងមធ្យោបាយពន្យារកំណើតទំនើប ជាពិសេសដល់ស្ត្រីដែលរស់នៅតំបន់ជនបទ។**

៣៨. ខណៈដែលកត់សម្គាល់នូវផ្តល់ប័ណ្ណក្រីក្រសម្រាប់ទទួលបានសេវាសុខាភិបាល ដោយប្រជាជនក្រីក្រ គណៈកម្មាធិការមានការព្រួយបារម្ភដែលស្ត្រីក្រីក្រ ស្ត្រីទេសន្តប្រវេសន៍បម្រើការងារតាមផ្ទះ ស្ត្រីពិការ និងស្ត្រីចាស់ជរាជួបការលំបាក ក្នុងការទទួលបានសេវាសុខាភិបាល។

៣៩. **គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី:**

**(ក) ពង្រឹងការអនុវត្តកម្មវិធី និងគោលនយោបាយដែលមានគោលបំណងផ្តល់សេវាថែទាំសុខភាពដែលមានតម្លៃសមស្របដល់ស្ត្រី ជាពិសេសស្ត្រីក្រីក្រ ស្ត្រីពិការ និងស្ត្រីចាស់ជរា និង**

**(ខ) យកចិត្តទុកដាក់ជាពិសេស ចំពោះតម្រូវការផ្នែកសុខភាពរបស់ស្ត្រីពិការ ដោយធានាថាស្ត្រីទាំងនេះ ទទួលបានការថែទាំមុនសម្រាល និងសេវាសុខភាពបន្តពូជ។**

## ស្ត្រីជនបទ គ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុ

៤០. ខណៈដែលកត់សម្គាល់នូវកិច្ចប្រឹងប្រែងមួយចំនួនរបស់រដ្ឋភាគី ក្នុងការលើកកម្ពស់ជីវភាពរបស់ស្ត្រី និងបុរសដែលរស់នៅតំបន់ជនបទតាមរយៈកម្មវិធីអនាម័យ និងតម្លើងបណ្តាញអគ្គិសនីជនបទ គណៈកម្មាធិការមានការព្រួយបារម្ភ ដែលស្ត្រីជនបទនៅតែបន្តទទួលបាន សេវាមូលដ្ឋានបង្គន់ ទឹកស្អាត និងមានសុវត្ថិភាព ការអប់រំ ការងារ សេវាសុខាភិបាល ឥណទាន និងប្រាក់កម្ចីមានកម្រិត។ គណៈកម្មាធិការក៏កត់សម្គាល់ផងដែរថា ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិមានផលប៉ះពាល់ខ្លាំងដល់ស្ត្រី និងកុមារ ជាពិសេសនៅតំបន់ជនបទ។

៤១. **គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី:**

**(ក) បង្កើនកិច្ចប្រឹងប្រែងរបស់ខ្លួន ក្នុងការជួយសម្រួលឲ្យស្ត្រីជនបទទទួលសេវាមូលដ្ឋាន បង្គន់ ទឹកពិសាសុវត្ថិភាព ការអប់រំ ការងារ សេវាសុខាភិបាល ឥណទាន និងប្រាក់កម្ចី។ ក្នុងន័យនេះ រដ្ឋភាគីគប្បីពិចារណាលើការបញ្ចូលបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន ក្នុង យុទ្ធសាស្ត្រការផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី សម្រាប់ស្ត្រីដែលរស់នៅតំបន់ជនបទ។**

**(ខ) បង្កើតសូចនាករ ដែលឆ្លុះបញ្ចាំងបានល្អប្រសើរពីការផ្លាស់ប្តូរតំបន់ និងការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម ជាផ្នែកមួយនៃការប្រឹងប្រែងរបស់ខ្លួនក្នុងការលើកកម្ពស់កម្មវិធីសុខភាព អប់រំ និងការងារសម្រាប់ស្ត្រីជនបទ និង**

**(គ) បន្តធានាថា ស្ត្រីចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេចទាំងក្នុងនយោបាយ និង**

កម្មវិធីទប់ស្កាត់ និងគ្រប់គ្រងគ្រោះមហន្តរាយ ជាពិសេសគោលនយោបាយ និងកម្មវិធីទាក់ទងនឹងការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

## ការទទួលបានដីធ្លី

៤២. ខណៈដែលទទួលស្គាល់នូវកិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ដើម្បីធ្វើឲ្យប្រសើរឡើងក្នុងការទទួលបានដីធ្លី ដូចជាការដាក់ចេញនូវអនុក្រិត្យ ដែលបានធ្វើអនុប្បយោគដីសាធារណៈជាដីឯកជន និងការដោះមីនកប់ដីនៅក្នុងភាគពាយ័ព្យនៃរដ្ឋភាគី គណៈកម្មាធិការមានការព្រួយបារម្ភ ថាស្ត្រីនៅតែទទួលបានដីធ្លី និងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីតិចតួច។ គណៈកម្មាធិការមានការព្រួយបារម្ភជាពិសេសដែលស្ត្រីទទួលរងនូវការផ្លាស់ទីលំនៅ និងការបណ្តេញចេញ ដោយសារសម្បទានដីទ្រង់ទ្រាយធំ និងការអភិវឌ្ឍន៍ក្រុង។ គណៈកម្មាធិការក៏ព្រួយបារម្ភផងដែរ ដែលតំបន់តាំងលំនៅដ្ឋានថ្មី ដែលត្រូវបានផ្តល់ដល់ជនរងគ្រោះ ដោយការការបណ្តេញចេញជាញឹកញាប់ខ្វះខាតហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងសេវាសំខាន់ៗ ដូចជា ទឹក អនាម័យ និងការថែទាំសុខភាពជាមូលដ្ឋាន ដែលប៉ះពាល់ដល់ស្ត្រីយ៉ាងខ្លាំង។ គណៈកម្មាធិការក៏មានកង្វល់ជាបន្តទៀត ថាស្ត្រីជាអ្នកការពារសិទ្ធិមនុស្សដែលតស៊ូមតិដើម្បីសិទ្ធិដីធ្លីរបស់ស្ត្រីជារឿយៗត្រូវស្ថិតក្រោមការបំភិតបំភ័យ និងការបៀតបៀនពីសំណាក់មន្ត្រីអនុវត្តច្បាប់។

៤៣. គណៈកម្មាធិការទទូចឲ្យរដ្ឋភាគី:

(ក) ធ្វើឲ្យប្រសើរឡើងនូវការទទួលបានដីធ្លី និងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីសម្រាប់ស្ត្រី ជានាថា លទ្ធកម្មដីធ្លីសម្រាប់សម្បទានសេដ្ឋកិច្ច និងសម្បទានផ្សេងទៀត គោរពតាមដំណើរការសមស្រប និងធានាថាសំណងគ្រប់គ្រាន់ត្រូវបានផ្តល់ បន្ទាប់ពីដំណើរការពិគ្រោះយោបល់គ្រប់គ្រាន់។

(ខ) ទទួលស្គាល់ ថាការបណ្តេញចេញដោយបង្ខំ មិនមែនជាហេតុការណ៍ដែលមានអព្យាក្រិត្យភាព យេនឌ័រនោះទេ (បាតុភូតយេនឌ័ ឬលម្អៀង) ប៉ុន្តែវាមានផលប៉ះពាល់ដល់ស្ត្រីច្រើនជាង និងចាត់វិធានការបន្ទាន់ ដើម្បីការពារស្ត្រី និងកុមារពីការបណ្តេញចេញបន្ថែមទៀត។

(គ) ស៊ើបអង្កេតជាបន្ទាន់ និងក្នុងករណីសមស្រប ធ្វើការចោទប្រកាន់លើករណី បំភិតបំភ័យ និងបៀតបៀន ដែលត្រូវបានប្រព្រឹត្តដោយមន្ត្រីអនុវត្តច្បាប់លើស្ត្រីជាអ្នកការពារសិទ្ធិមនុស្ស ដែលតស៊ូមតិដើម្បី សិទ្ធិដីធ្លី និង

(ឃ) ធានាថា សហគមន៍ដែលត្រូវបានបណ្តេញចេញ ត្រូវបានផ្លាស់ទីលំនៅទៅកាន់តំបន់ដែលអាចជួយឲ្យស្ត្រីងាយស្រួលក្នុងការទៅមកកន្លែងធ្វើការ សាលារៀន មណ្ឌលសុខភាព (រាប់បញ្ចូលទាំងការថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ) មជ្ឈមណ្ឌលសហគមន៍ សេវា និងទីកន្លែងផ្សេងៗទៀតដែលចាំបាច់ក្នុងការធានានូវការសម្រេចបានសិទ្ធិមនុស្ស របស់ពួកគេស្របតាមអនុសញ្ញានេះ។

## ក្រុមស្ត្រីដែលបាត់បង់ឱកាស

៤៤. គណៈកម្មាធិការមានការព្រួយបារម្ភចំពោះការខ្វះខាតទិន្នន័យបែងចែកតាមអាយុ និងភេទដែលអាចត្រូវបានប្រើប្រាស់ ដើម្បីវាយតម្លៃវិសាលភាពនៃការរើសអើងលើស្ត្រីចាស់ជរា និងការរើសអើងលើស្ត្រីចាស់ជរា ជាពិសេសក្នុងការទទួលបានសេវាថែទាំសុខភាព និងសន្តិសុខសង្គម។

៤៥. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីប្រមូល និងវិភាគទិន្នន័យដោយបែងចែកតាមអាយុ

និងភេទសម្រាប់ធ្វើគោលនយោបាយ និងអនុវត្តវិធីសាស្ត្ររយៈពេលយូរសម្រាប់ដោះស្រាយការរើសអើងលើស្ត្រីចាស់ជរា។

## អាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ

៤៦. គណៈកម្មាធិការសោកស្តាយដែលរដ្ឋភាគីនៅតែរក្សាបញ្ញត្តិនៃមាត្រា៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលពន្យារពេលស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រីដល់១២០ថ្ងៃ បន្ទាប់ប្តីស្លាប់ ឬបន្ទាប់ពីតុលាការចេញសាលក្រមសម្រេចឲ្យលែងលះ។ គណៈកម្មាធិការមានការព្រួយបារម្ភថា នេះគឺជាបញ្ញត្តិដែលមានការរើសអើង ពីព្រោះវាមិនអនុវត្តចំពោះបុរស និងតាមរបាយការណ៍ ថាបញ្ញត្តិនេះ ព្យាយាមជួយដល់ការបង្កើតបិតុភាពរបស់កុមារ។ គណៈកម្មាធិការក៏ព្រួយបារម្ភផងដែរ ថាគូស្រករដែលបានរៀបការតាមច្បាប់ប្រពៃណីជួបការលំបាកច្រើនក្នុងការធ្វើឲ្យអាពាហ៍ពិពាហ៍របស់ពួកគេមានលក្ខណៈផ្លូវការ។

៤៧. គណៈកម្មាធិការជំរុញឲ្យរដ្ឋភាគីធ្វើនិរាករណ៍លើមាត្រា៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលមានលក្ខណៈរើសអើង និងរិតត្បឹតដោយមិនសមស្របនូវសិទ្ធិរបស់ស្ត្រីក្នុងការរៀបការម្តងទៀត ពីព្រោះបិតុភាពអាចត្រូវបានបង្កើតឡើងយ៉ាងងាយស្រួល ដោយមធ្យោបាយដែលមិនសូវរិតត្បឹតក្នុងវិស័យវេជ្ជសាស្ត្រ។ គណៈកម្មាធិការក៏ផ្តល់អនុសាសន៍ផងដែរឲ្យរដ្ឋភាគីចាត់វិធានការនានាដើម្បីសម្រួលដល់ការរៀបការតាមរយៈច្បាប់ប្រពៃណីមានលក្ខណៈផ្លូវការ ដោយការធានាថា ការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍មានតម្លៃសមរម្យ និងគ្មានបន្ទុកខ្លាំង។

## សេចក្តីប្រកាស និងផែនការសកម្មភាពក្រុងប៉េកាំង

៤៨. គណៈកម្មាធិការអំពាវនាវឲ្យរដ្ឋភាគីប្រើប្រាស់សេចក្តីប្រកាស និងផែនការសកម្មភាព ក្រុងប៉េកាំង ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការអនុវត្តបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ។

## គោលដៅអភិវឌ្ឍន៍សហសវត្ស និងក្របខណ្ឌអនាគត

៤៩. គណៈកម្មាធិការអំពាវនាវឲ្យរដ្ឋភាគីបញ្ចូលទស្សនៈយេនឌ័រ ស្របតាមបញ្ញត្តិនៃអនុសញ្ញាក្នុងរាល់កិច្ចប្រឹងប្រែងដែលមានគោលបំណង ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្ស និងក្របខណ្ឌអភិវឌ្ឍន៍ថ្មីត្រឹមឆ្នាំ២០១៥។

### ការបន្តអនុវត្តការសង្កេតសន្និដ្ឋាន

៥០. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានជាលាយលក្ខអក្សរអំពីវិធានការ ដែលត្រូវបានចាត់ឡើងក្នុង ការអនុវត្តអនុសាសន៍ក្នុងកថាខណ្ឌទី១៥ និង២១ ចំណុច (ក), (ខ) និង (គ) ក្នុងរយៈពេលពីរឆ្នាំ។

### ការរៀបចំរបាយការណ៍លើកក្រោយ

៥១.គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីដាក់ជូនរបាយការណ៍គួបលើកទី៦ ក្នុងខែតុលា ឆ្នាំ២០១៧។

៥២.គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីគោរពតាម "គោលការណ៍ណែនាំសុខុដុមនីយកម្ម

---

*ស្តីពីការរាយការណ៍ស្របតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិរាប់បញ្ចូលទាំងគោលការណ៍ណែនាំស្តីពីឯកសារគោលរួម និងឯកសារសន្ធិសញ្ញានីមួយៗ" (HRI/MC/2006/3 និង Corr.1)។*